ตสฺมา ตถาคตสฺส ปรินิพฺพานกาโล
อนิยมิโต ปรินิพฺพานกาโล นาม โหติ ฯ
เอวมยมฺปิ ปรินิพฺพานกาโล นาม ตถาคตสฺส
ปรินิพฺพายนฺตสฺส ปฐมยามาทีสุ ยสฺมา
กสฺสจิ ปรินิพฺพานกาโล โหติ ตสฺมา

មរណៈ(របស់បុគ្គលនោះ)ក៏ល្អ កាលកិរិយាក៏ល្អ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល ដែលបុគ្គលប្រក់ជិតល្អហើយ កំពូលក៏រក្សាទុកបាន បង្គន់ក៏រក្សាទុកបាន ជញ្ជាំងក៏រក្សាទុកបាន កំពូលក៏មិនទទឹកជោក បង្គន់ក៏មិនទទឹកជោក ជញ្ជាំងក៏មិនទទឹកជោក កំពូលក៏មិនពុក បង្គន់ក៏មិនពុក ជញ្ជាំងក៏មិនពុក យ៉ាងណា ម្នាលគហបតី កាលបើចិត្តដែលបុគ្គលរក្សាហើយ ។បេ។ មរណៈក៏ល្អ កាលកិរិយាក៏ល្អ យ៉ាងនោះដែរ ។

[๑๑๒] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី កាលបើចិត្តព្យាបាទហើយ ឈ្មោះកម្មក៏ព្យាបាទតាមដែរ វចីកម្មក៏ព្យាបាទតាមដែរ មនោកម្មក៏ព្យាបាទតាមដែរ ។ កាលបុគ្គលនោះ មានកាយកម្មប្រកបដោយព្យាបាទ មានវចីកម្មប្រកបដោយព្យាបាទ មានមនោកម្មប្រកបដោយព្យាបាទហើយ មរណៈ (របស់បុគ្គលនោះ) ក៏មិនល្អទេ កាលកិរិយាក៏មិនល្អទេ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល

ទុច្ចរិតេ កម្មជំ ព្យាបជ្ជំ ហោតិ គោចារណ-
សិយោបិ ព្យាបជ្ជា ហោន្តិ អាវុដ្ឋិបិ ព្យាបជ្ជា ហោតិ
ឱវរមេវ ខោ កហាបតិ ចិត្តេ ព្យាបន្នេ ។ បេ ។ ន
ភទ្ទកំ មរណំ ហោតិ ន ភទ្ទិកា កាលកិរិយា ។
ចិត្តេ តរហាបតិ អព្យាបន្នេ កាយកម្មម្បិ អព្យាបជ្ជំ
ហោតិ វចីកម្មម្បិ អព្យាបជ្ជំ ហោតិ មនោកម្មម្បិ
អព្យាបជ្ជំ ហោតិ ។ តស្ស អព្យាបជ្ជកាយកម្មស្ស
អព្យាបជ្ជវចីកម្មស្ស អព្យាបជ្ជមនោកម្មស្ស ភទ្ទកំ
មរណំ ហោតិ ភទ្ទិកា កាលកិរិយា ។ សេយ្យថាបិ
កហាបតិ ក្ខុជាតរេ សុច្ចន្នេ ក្ខុជម្បិ អព្យាបជ្ជំ
ហោតិ គោចារណសិយោបិ អព្យាបជ្ជា ហោន្តិ អាវុដ្ឋិបិ
អព្យាបជ្ជា ហោតិ ឱវរមេវ ខោ កហាបតិ ចិត្តេ
អព្យាបន្នេ ។ បេ ។ ភទ្ទកំ មរណំ ហោតិ
ភទ្ទិកា កាលកិរិយាតិ ។

[๑๑๓] តីណីមានិ ភិក្ខវេ ឯឆាជានិ កម្មានំ
សមុទយាយ ។ កតមានិ តីណិ ។ លោភោ ឯឆាជំ

ដែលបុគ្គលប្រកបមិនជិត កំពូលក៏ខូចផង បង្គន់ក៏ខូចផង ជញ្ជាំងក៏ខូចផង ម្នាលគហបតី កាលបើចិត្តព្យាបាទហើយ ។ បេ ។ មរណៈក៏មិនល្អ កាលកិរិយាន ក៏មិនល្អ ដូច្នោះដែរ ។ ម្នាលគហបតី កាលបើចិត្ត មិនព្យាបាទ ហើយកាយកម្មក៏មិនព្យាបាទតាម វចីកម្មក៏មិនព្យាបាទតាម មនោកម្មក៏មិនព្យាបាទតាម ។ កាលបុគ្គលនោះ មានកាយកម្ម មិនប្រកបដោយព្យាបាទ មានវចីកម្ម មិនប្រកបដោយព្យាបាទ មានមនោកម្ម មិនប្រកបដោយព្យាបាទហើយ មរណៈក៏ល្អ កាលកិរិយាក៏ល្អ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល ដែលបុគ្គលប្រកបជិត កំពូលក៏មិនខូចផង បង្គន់ក៏មិនខូចផង ជញ្ជាំងក៏មិនខូចផង ម្នាលគហបតី កាលបើចិត្តមិនព្យាបាទហើយ ។ បេ ។ មរណៈក៏ល្អ កាលកិរិយាក៏ល្អ ដូច្នោះដែរ ។

(១១៣) ម្នាលភិក្ខុទាំងឡាយ ហេតុនេះមាន ៣ យ៉ាង នៃការកើតឡើងនៃកម្ម ។ ហេតុ ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺលោភៈជាហេតុ

កម្មានំ សមុទយាយ នោសោ និធានំ
កម្មានំ សមុទយាយ មោហោ និធានំ កម្មានំ
សមុទយាយ ។ យំ កិញ្ចិ លោកប្បកតំ កម្មំ
លោកដំ លោកនិធានំ លោកសមុទយំ តំ កម្មំ
អកុសលំ តំ កម្មំ សាវជ្ជំ តំ កម្មំ ទុក្ខវិបាកំ
តំ កម្មំ កម្មសមុទយាយ សំវត្តតិ ន តំ កម្មំ
កម្មនិរោធាយ សំវត្តតិ ។ យំ កិញ្ចិ នោសប្បកតំ
កម្មំ នោសដំ នោសនិធានំ នោសសមុទយំ តំ កម្មំ
អកុសលំ តំ កម្មំ សាវជ្ជំ តំ កម្មំ ទុក្ខវិបាកំ
តំ កម្មំ កម្មសមុទយាយ សំវត្តតិ ន តំ កម្មំ
កម្មនិរោធាយ សំវត្តតិ ។ យំ កិញ្ចិ មោហប្បកតំ
កម្មំ មោហដំ មោហនិធានំ មោហសមុទយំ តំ កម្មំ
អកុសលំ តំ កម្មំ សាវជ្ជំ តំ កម្មំ ទុក្ខវិបាកំ
តំ កម្មំ កម្មសមុទយាយ សំវត្តតិ ន តំ កម្មំ
កម្មនិរោធាយ សំវត្តតិ ។ ឥមានិ ខោ កិញ្ចិ តីណិ
និធានានិ កម្មានំ សមុទយាយ ។ តីណីមានិ កិញ្ចិ
និធានានិ កម្មានំ សមុទយាយ ។ កតមានិ តីណិ ។

នៃការកើតឡើងនៃកម្ម ១ ទោសៈជាហេតុនៃការកើតឡើងនៃកម្ម ១ មោហៈជាហេតុនៃការកើតឡើងនៃកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មណា សម្រេចមកអំពីលោភៈ កើតមកអំពីលោភៈ មានលោភៈជាហេតុ មានលោភៈជាដែនកើត កម្មនោះជាអកុសល កម្មនោះប្រកបដោយទោស កម្មនោះមានទុក្ខជាវិបាក កម្មនោះប្រព្រឹត្តទៅដើម្បីកើតឡើងនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីទោសៈ កើតមកអំពីទោសៈ មានទោសៈជាហេតុ មានទោសៈជាដែនកើត កម្មនោះជាអកុសល កម្មនោះប្រកបដោយទោស កម្មនោះមានទុក្ខជាវិបាក កម្មនោះប្រព្រឹត្តទៅដើម្បីកើតឡើងនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីមោហៈ កើតមកអំពីមោហៈ មានមោហៈជាហេតុ មានមោហៈជាដែនកើត កម្មនោះជាអកុសល កម្មនោះប្រកបដោយទោស កម្មនោះមានទុក្ខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម កម្មនោះ មិនប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះឯង ដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះ ដើម្បីកើតឡើងនៃកម្ម ។ ហេតុ ៣ យ៉ាងដូចម្តេចខ្លះ ។

អលោភោ និធានំ កម្មានំ សមុទយាយ អទោសោ និធានំ កម្មានំ សមុទយាយ អមោហោ និធានំ កម្មានំ សមុទយាយ ។ យំ ភិក្ខវេ អលោភប្បកតំ កម្មំ អលោភជំ អលោភនិធានំ អលោភសមុទយំ តំ កម្មំ កុសលំ តំ កម្មំ អនវជ្ជំ តំ កម្មំ សុខវិបាកំ តំ កម្មំ កម្មនិរោធាយ សំវត្តតិ ន តំ កម្មំ កម្មសមុទយាយ សំវត្តតិ ។ យំ ភិក្ខវេ អទោសប្បកតំ កម្មំ អទោសជំ អទោសនិធានំ អទោសសមុទយំ តំ កម្មំ កុសលំ តំ កម្មំ អនវជ្ជំ តំ កម្មំ សុខវិបាកំ តំ កម្មំ កម្មនិរោធាយ សំវត្តតិ ន តំ កម្មំ កម្មសមុទយាយ សំវត្តតិ ។ យំ ភិក្ខវេ អមោហប្បកតំ កម្មំ អមោហជំ អមោហនិធានំ អមោហសមុទយំ តំ កម្មំ កុសលំ តំ កម្មំ អនវជ្ជំ តំ កម្មំ សុខវិបាកំ តំ កម្មំ កម្មនិរោធាយ សំវត្តតិ ន តំ កម្មំ កម្ម-សមុទយាយ សំវត្តតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ និធានានិ កម្មានំ សមុទយាយាតិ ។

គឺអលោភៈជាហេតុ នៃការកើតឡើងនៃកម្ម ១ អទោសៈជាហេតុ នៃការកើតឡើងនៃកម្ម ១ អមោហៈជាហេតុ នៃការកើតឡើងនៃកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីអលោភៈ កើតមកអំពីអលោភៈ មានអលោភៈជាហេតុ មានអលោភៈជាដែនកើតកម្មនោះ ជាកុសល កម្មនោះឥតទោស កម្មនោះមានសុខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីអទោសៈ កើតមកអំពីអទោសៈ មានអទោសៈជាហេតុ មានអទោសៈជាដែនកើតកម្មនោះ ជាកុសល កម្មនោះឥតទោស កម្មនោះមានសុខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីអមោហៈ កើតមកអំពីអមោហៈ មានអមោហៈជាហេតុ មានអមោហៈជាដែនកើតកម្មនោះជាកុសល កម្មនោះឥតទោស កម្មនោះមានសុខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះឯង ដើម្បីកើតឡើងនៃកម្ម ។

(๑๑๔) ตีณิมานิ ภิกฺขเว ทิวาทานิ กมฺมานิ สมุฏฺฐเปนฺติ ฯ กตมานิ ตีณิ ฯ อตีตเต ภิกฺขเว ฉนฺทกถาวีริยเหตุ ฉนฺโท อาวฏฺฏติ ฉนฺโท ชายติ อนาคตเต ภิกฺขเว ฉนฺทกถาวีริยเหตุ ฉนฺโท อาวฏฺฏติ ฉนฺโท ชายติ ปจฺจุปฺปนฺเน ภิกฺขเว ฉนฺทกถาวีริยเหตุ ฉนฺโท อาวฏฺฏติ ฉนฺโท ชายติ ฯ กถญฺจ ภิกฺขเว อตีตเต ฉนฺทกถาวีริยเหตุ ฉนฺโท อาวฏฺฏติ ฉนฺโท ชายติ ฯ อตีตเต ภิกฺขเว ฉนฺทกถาวีริยเหตุ ฉนฺโท อาวฏฺฏติ เจตสา อนุวิตกฺกติ อนุวิจารเต ฯ ตสฺส อตีตเต ฉนฺทกถาวีริยเหตุ ฉนฺโท อาวฏฺฏติ เจตสา อนุวิตกฺกยโต อนุวิจารยโต ฉนฺโท ชายติ ฉนฺทชาโต เตหิ ธมฺเมหิ สมฺปยุตฺโต โหติ ฯ เอวเมวํ ภิกฺขเว สญฺโญชนิยานิ ธมฺมา โย เจตสา สาทิยติ ฯ เอวมฺปิ โข ภิกฺขเว อตีตเต ฉนฺทกถาวีริยเหตุ ฉนฺโท อาวฏฺฏติ ฉนฺโท ชายติ ฯ กถญฺจ ภิกฺขเว อนาคตเต ฉนฺทกถาวีริยเหตุ ฉนฺโท อาวฏฺฏติ ฉนฺโท ชายติ ฯ

[๑๑๔] ម្នាលភិក្ខុទាំងឡាយ ហេតុ ๓ យ៉ាងនេះ ដើម្បីកើតឡើងនៃកម្ម ។ ๓ យ៉ាងតើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃធន្មុពគជាអតីត ๑ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃធន្មុពគជាអនាគត ๑ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃធន្មុពគជាបច្ចុប្បន្ន ๑ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តកើតឡើងព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃធន្មុពគជាអតីតដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃធន្មុពគជាអតីត ។ កាលបុគ្គលនោះ មានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ប្រារព្ធនូវធម៌ ជាទីតាំងនៃធន្មុពគជាអតីត សេចក្តីគាប់ចិត្តក៏កើតឡើង បុគ្គលនោះ លុះមានសេចក្តីគាប់ចិត្តកើតឡើងហើយ តែងប្រកបដោយធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចិត្ត ដែលប្រកបដោយពាគៈ ថា ជាសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃធន្មុពគជាអតីត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃធន្មុពគជាអនាគតដូចម្តេច ។

อนาคเต ภิกฺขเว ฉนฺนภิชฺฌานีเย ฉมฺเห อาวฏฺเฏ เจตสา อนุวิตกฺกิเต อนุวิจาเรติ ฯ ตสฺส อนาคเต ฉนฺนภิชฺฌานีเย ฉมฺเห อาวฏฺเฏ เจตสา อนุวิตกฺกิ-ยเตา อนุวิจารยเตา ฉนฺโน ชายติ ฉนฺทชาเตา เตหิ ฉมฺเหหิ สมฺยุตฺโต โหติ ฯ เอตมหำ ภิกฺขเว สญฺโญชนำ วทามิ โย เจตสเก สาทเตา ฯ

ปุน โจ ภิกฺขเว อนาคเต ฉนฺนภิชฺฌานีเย ฉมฺเห อาวฏฺเฏ ฉนฺโน ชายติ ฯ กถญฺจ ภิกฺขเว ปจฺจุปฺปนฺเน ฉนฺนภิชฺฌานีเย ฉมฺเห อาวฏฺเฏ ฉนฺโน ชายติ ฯ ปจฺจุปฺปนฺเน ภิกฺขเว ฉนฺนภิชฺฌานีเย ฉมฺเห อาวฏฺเฏ เจตสา อนุวิตกฺกิเต อนุวิจาเรติ ฯ ตสฺส ปจฺจุปฺปนฺเน ฉนฺนภิชฺฌานีเย ฉมฺเห อาวฏฺเฏ เจตสา อนุวิตกฺกิ-ยเตา อนุวิจารยเตา ฉนฺโน ชายติ ฉนฺทชาเตา เตหิ ฉมฺเหหิ สมฺยุตฺโต โหติ ฯ เอตมหำ ภิกฺขเว สญฺโญชนำ วทามิ โย เจตสเก สาทเตา ฯ

ម្នាលភិក្ខុទាំងឡាយ បុគ្គលមានចិត្តត្រេកអរហើយ ។ ពិចារណារឿយៗព្រោះ
ប្រារព្ធនូវធម៌ ជាទីតាំងនៃធន្មុពគ ជាអនាគត ។ កាលបុគ្គលនោះ មានចិត្ត
ត្រេកអរហើយ ។ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃធន្មុពគ
ជាអនាគត សេចក្តីគាប់ចិត្តក៏កើតឡើង បុគ្គលនោះ លុះមានសេចក្តីគាប់
ចិត្តកើតឡើងហើយ តែងប្រកបដោយធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ
តថាគតពោលនូវចិត្តដែលប្រកបដោយពគៈថា ជាសញ្ញោជនៈ ។ ម្នាលភិក្ខុ
ទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវ
ធម៌ ជាទីតាំងនៃធន្មុពគ ជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់
ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃធន្មុពគ ជាបច្ចុប្បន្នដូចម្តេច ។
ម្នាលភិក្ខុទាំងឡាយ កាលបុគ្គល មានចិត្តត្រេកអរហើយ ។ ពិចារណារឿយៗ
ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃធន្មុពគ ជាបច្ចុប្បន្ន ។ កាលបុគ្គលនោះ
មានចិត្តត្រេកអរហើយ ។ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃ
ធន្មុពគជាបច្ចុប្បន្ន សេចក្តីគាប់ចិត្តក៏កើតឡើង បុគ្គលនោះ លុះមានសេចក្តី
គាប់ចិត្តកើតឡើងហើយ តែងប្រកបដោយធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំង
ឡាយ តថាគត ពោលនូវចិត្ត ដែលប្រកបដោយពគៈថា ជាសញ្ញោជនៈ ។

ឯវំ ខោ កិក្ខវេ បច្ចុប្បន្នេ ឆន្ទរាគប្បហានំយេ ឆម្ភេ អារព្ភ ឆន្ទោ ជាយតិ ។ ឥមានិ ខោ កិក្ខវេ តីណិ និទានានិ កម្មានំ សមុទយាយ ។ តីណិមានិ កិក្ខវេ និទានានិ កម្មានំ សមុទយាយ ។ កតមានិ តីណិ ។ អតីតេ កិក្ខវេ ឆន្ទរាគប្បហានីយេ ឆម្ភេ អារព្ភ ឆន្ទោ ន ជាយតិ អនាគតេ កិក្ខវេ ឆន្ទរាគប្បហានីយេ ឆម្ភេ អារព្ភ ឆន្ទោ ន ជាយតិ បច្ចុប្បន្នេ កិក្ខវេ ឆន្ទរាគប្បហានីយេ ឆម្ភេ អារព្ភ ឆន្ទោ ន ជាយតិ ។ កថញ្ច កិក្ខវេ អតីតេ ឆន្ទរាគប្បហានីយេ ឆម្ភេ អារព្ភ ឆន្ទោ ន ជាយតិ ។ អតីតានំ កិក្ខវេ ឆន្ទរាគប្បហានីយានំ ឆម្ភានំ អាយតឹ វិបាកំ បជានាតិ អាយតឹ វិបាកំ វិទិត្វា តទភិនិវជ្ជេតិ តទភិនិវជ្ជេត្វា ខេតសា អភិវិភវេត្វា (១) បញ្ញាយ អតិវិជ្ឈ បស្សតិ ។ ឯវំ ខោ កិក្ខវេ អតីតេ ឆន្ទរាគប្បហានីយេ ឆម្ភេ អារព្ភ ឆន្ទោ ន ជាយតិ ។ កថញ្ច កិក្ខវេ អនាគតេ ឆន្ទរាគប្បហានីយេ ឆម្ភេ អារព្ភ ឆន្ទោ ន ជាយតិ ។

---

១ ម· អភិនិវិជ្ឈិត្វា ។

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃធម្មារម្មណ៍ជាបច្ចុប្បន្ន។ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាហេតុ ៣ យ៉ាង នៃការកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះ ដើម្បីកើតឡើងនៃកម្ម ។ ៣ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃធម្មារម្មណ៍ជាអតីត ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃធម្មារម្មណ៍ ជាអនាគត ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃធម្មារម្មណ៍ជាបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃធម្មារម្មណ៍ជាអតីត ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងច្បាស់នូវវិបាកនៃធម៌ទាំងឡាយ ជាទីតាំងនៃធម្មារម្មណ៍ជាអតីតកាល លុះដឹងនូវវិបាកកាលហើយ ក៏លះបង់វិបាកនោះ លុះលះបង់វិបាកនោះហើយ ទើបមានចិត្តឯឡើយណាយ ហើយចាក់ផ្ទុះឃើញច្បាស់ ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃធម្មារម្មណ៍ជាអតីត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃធម្មារម្មណ៍ជាអនាគត ដូចម្តេច ។

អនាគតអទ្ធានំ តិក្ខត្តុំ ឆន្នភកដ្ឋានីយានំ ឆន្នំ អាយតឹ វិចាតកំ បជានាតិ អាយតឹ វិចាតកំ វិនិគ្ឆា តនកិនិវដ្ដតិ តនកិនិវដ្ដគ្ឆា ចេតសា អភិវិភវេគ្ឆា បញ្ញាយ អតិវិជ្ឈ បស្សតិ ។ ឯវំ ខោ តិក្ខត្តុំ អនាគតេ ឆន្នភកដ្ឋានីយេ ធម្មេ អារព្ភ ឆន្នោ ន ជាយតិ ។ កថញ្ច តិក្ខត្តុំ បច្ចុប្បន្នេ ឆន្នភកដ្ឋានីយេ ធម្មេ អារព្ភ ឆន្នោ ន ជាយតិ ។ បច្ចុប្បន្នានំ តិក្ខត្តុំ ឆន្នភកដ្ឋានីយានំ ឆន្នានំ អាយតឹ វិចាតកំ បជានាតិ អាយតឹ វិចាតកំ វិនិគ្ឆា តនកិនិវដ្ដតិ តនកិនិវដ្ដគ្ឆា ចេតសា អភិវិភវេគ្ឆា បញ្ញាយ អតិវិជ្ឈ បេស្សតិ ។ ឯវំ ខោ តិក្ខត្តុំ បច្ចុប្បន្នេ ឆន្នភកដ្ឋានីយេ ធម្មេ អារព្ភ ឆន្នោ ន ជាយតិ ។ ឥមានិ ខោ តិក្ខត្តុំ តីណិ និទានានិ កម្មានំ សមុទយាយាតិ ។

សម្ពោធិវគ្គោ ឆដ្ឋោ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងច្បាស់នូវវិបាកនៃធម៌ទាំងឡាយ ជាទីតាំងនៃធន្លុកគ ជាអនាគតតាំង លុះដឹងច្បាស់នូវវិបាកតាំហើយ ក៏លះបង់នូវវិបាកនោះ លុះលះបង់វិបាកនោះហើយ ទើបមានចិត្តនឿយណាយ ហើយចាក់ធ្លុះឃើញច្បាស់ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថាសេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រាវត្តធម៌ ជាទីតាំងនៃធន្លុកគជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រាវត្តធម៌ ជាទីតាំងនៃធន្លុកគជាបច្ចុប្បន្ន ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងច្បាស់នូវវិបាកនៃធម៌ទាំងឡាយ ជាទីតាំងនៃធន្លុកគជាបច្ចុប្បន្នតាំ លុះដឹងច្បាស់នូវវិបាកតាំហើយ ក៏លះបង់នូវវិបាកនោះ លុះលះបង់វិបាកនោះហើយ ទើបមានចិត្តនឿយណាយ ហើយចាក់ធ្លុះ ឃើញច្បាស់ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រាវត្តធម៌ ជាទីតាំងនៃធន្លុកគជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង៣ យ៉ាងនេះឯង ដើម្បីកើតឡើងនៃកម្ម ។

ចប់ សម្ពោធិវគ្គទី ១ ។

តតិយំ

បុព្វេ មនុស្សេ អស្សាទោ
សមណោ ពោធាយ បញ្ចមំ
អតិត្តា ទ្វេ ច កុជ្ឈនិ
ឯធាធា អបរេ ទុវេតិ ។

ទុតិយនៃសម្ពោធិវគ្គោះគឺ

និយាយអំពីកាលមុនត្រាស់ដឹង ១ អំពីគានិសង្ស ផាដើមកង៏មនុស្ស ១ អំពីសមណព្រាហ្មណ៍ ១ អំពីសេចក្តីយំស្រែកមួយទៀតជាគំរប់ក្រុំ ១ អំពីការសេពមិនបេះផ្អែត ១ អំពីផ្ទះមានកំពូលមានពីរលើក ១ អំពីហេតុដទៃទៀត មានពីរលើក ១ ។

អាបាយិករាគ្គោ

(១១៥) តយោមេ ភិក្ខវេ អាចាយិកា នេរយិកា ឧទមប្បហាយ ។ កតមេ តយោ ។ យោ ច អព្រហ្មចារី ព្រហ្មចារិប្បដិញ្ញោ យោ ច សុទ្ធព្រហ្មចារី សុទ្ធំ ព្រហ្មចរិយំ ចរន្តំ អមូលកេន អព្រហ្មចរិយេន អនុទ្ធំសេតិ យោ ចាយំ ឃរំភេទី ឃរំទិដ្ឋិ នត្តំ កាមេសុ នោសោតិ សោ កាមេសុ ចាតព្យតំ អាបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ តយោ អាចាយិកា នេរយិកា ឧទមប្បហាយាតិ ។

(១១៦) តិណ្ណំ ភិក្ខវេ ចាតុកាកៅ ធុល្យកោ លោកស្មឹ ។ កតមេសំ តិណ្ណំ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស ចាតុកាកៅ ធុល្យកោ លោកស្មឹ តថាគតប្បវេទិតស្ស ធម្មវិនយស្ស នេសេតា បុគ្គលោ ធុល្យកោ លោកស្មឹ កតញ្ញូ កតវេទី បុគ្គលោ ធុល្យកោ លោកស្មឹ ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ចាតុកាកៅ ធុល្យកោ លោកស្មឹតិ ។

អាបាយិកវគ្គ

(១១៥) ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ តែងទៅកាន់អបាយ ទៅកាន់នរក ព្រោះមិនលះបង់អំពើអាក្រក់នេះ ។ បុគ្គល ៣ ពួក ដូចម្តេចខ្លះ ។ គឺបុគ្គលណា មិនមែនជាព្រហ្មចារ្យ តែប្តេជ្ញាថាខ្លួនជាព្រហ្មចារ្យ ១ បុគ្គលណា ចោទបុគ្គលជាព្រហ្មចារ្យ បរិសុទ្ធ ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ដោយអព្រហ្មចរិយធម៌មិនមានមូល ១ បុគ្គលណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទោសកថាកាមទាំងឡាយមិនមាន បុគ្គលនោះ ក៏ដល់នូវសេចក្តីស្រេកឃ្លានក្នុងកាមទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៣ ពួកនេះ តែងទៅកាន់អបាយ ទៅកាន់នរក ព្រោះមិនលះបង់អំពើអាក្រក់នេះ ។

(១១៦) ម្នាលភិក្ខុទាំងឡាយ សេចក្តីកើតប្រាកដនៃបុគ្គល ៣ ពួក រកបានដោយក្រក្នុងលោក ។ បុគ្គល ៣ ពួកដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីកើតប្រាកដនៃព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ រកបានដោយក្រក្នុងលោក ១ បុគ្គលអ្នកសំដែងធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ រកបានដោយក្រក្នុងលោក ១ បុគ្គលជាកតញ្ញូកតវេទី រកបានដោយក្រក្នុងលោក ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គល ៣ ពួកនេះ រកបានដោយក្រក្នុងលោក ។

[១១៧] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិំ ។ កតមេ តយោ ។ សុប្បមេយ្យោ ទុប្បមេយ្យោ អប្បមេយ្យោ ។ កតមោ ច ភិក្ខវេ បុគ្គលោ សុប្បមេយ្យោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧទ្ធតោ ហោតិ ឧន្នឡោ ចបលោ មុខរោ វិកិណ្ណវាចោ មុដ្ឋស្សតិ អសម្បជានោ អសមាហិតោ វិព្ភន្តចិត្តោ ចាកតិន្ទ្រិយោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ សុប្បមេយ្យោ ។ កតមោ ច ភិក្ខវេ បុគ្គលោ ទុប្បមេយ្យោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អនុទ្ធតោ ហោតិ អនុន្នឡោ អចបលោ អមុខរោ អវិកិណ្ណវាចោ ឧបដ្ឋិតស្សតិ សម្បជានោ សមាហិតោ ឯកគ្គចិត្តោ សំវុតិន្ទ្រិយោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ ទុប្បមេយ្យោ ។ កតមោ ច ភិក្ខវេ បុគ្គលោ អប្បមេយ្យោ ។ ឥធ ភិក្ខវេ ភិក្ខុ អរហំ ហោតិ ខីណាសវោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អប្បមេយ្យោ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិំ ។

(១១៧) ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួកដូចម្តេចខ្លះ ។ គឺសុប្បមេយ្យបុគ្គល (បុគ្គលដែលគេប្រមាណដោយងាយ) ១ ទុប្បមេយ្យបុគ្គល (បុគ្គលដែលគេប្រមាណដោយក្រ) ១ អប្បមេយ្យបុគ្គល(បុគ្គលដែលគេប្រមាណមិនបាន) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសុប្បមេយ្យបុគ្គលដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកលើកតំណស់ ឆ្មើងឆ្មៃ រពើតរពើល មាត់រំដើ និយាយប៉ាច់ប៉ាច់ប៉ាច់ ក្ងេចស្មារតី មិនដឹងខ្លួន មានចិត្តមិននឹងធឹង មានចិត្តប្រែប្រួល មានឥន្ទ្រិយបើកចំហ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុប្បមេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចុះទុប្បមេយ្យបុគ្គលដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកមិនលើកតំណស់ មិនឆ្មើងឆ្មៃ មិនរពើតរពើល មិនមានមាត់រំដើ មិននិយាយប៉ាច់ប៉ាច់ប៉ាច់ ដំកល់ស្មារតី ដឹងខ្លួន មានចិត្តនឹងធឹង មានចិត្តមានអារម្មណ៍តែមួយ សង្រួមឥន្ទ្រិយល្អ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុប្បមេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចុះអប្បមេយ្យបុគ្គលដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺបានដល់ភិក្ខុ ជាអរហំ ខីណាស្រព ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អប្បមេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឯង រមែងមាននៅក្នុងលោក ។

(๑๑๘) តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិំ ។ កតមេ តយោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចា-យតនំ ឧបសម្បជ្ជ វិហរតិ ។ សោ តទនុធម្មតាយ តំ និកាមេតិ តេន ច វិត្តិំ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្ពហុលវិហារី អបរិហីនោ កាលំ ករុមានោ អាកាសានញ្ចាយតនូបគានំ ទេវានំ សហ-ព្យតំ ឧបបជ្ជតិ ។ អាកាសានញ្ចាយតនូបគានំ ភិក្ខវេ ទេវានំ វីសតិ កប្បសហស្សានិ អាយុប្បមាណំ ។ តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្ពំ ខេបេត្វា និរយម្បិ គច្ឆតិ តិរច្ឆានយោនិម្បិ គច្ឆតិ បិត្តិវិសយម្បិ គច្ឆតិ ។ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា

(១១៨) ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួកដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ព្រោះកន្លងបង់នូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះរលត់នូវបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ចូលកាន់អាកាសានញ្ចាយតនឈ្មាន ដោយយ៉ាងនេះថា អាកាសមិនមានទីបំផុតដូច្នេះ ។ បុគ្គលនោះ ត្រេកអរនឹងឈាននោះ ប្រាថ្នានូវឈាននោះ ដល់នូវសេចក្តីត្រេកអរនឹងឈាននោះ ស្ថិតនៅក្នុងឈាននោះ សម្រេកក្នុងឈាននោះ សម្រេចសម្រាន្តនៅដោយច្រើនក្នុងឈាននោះ មិនសាបសូន្យ (ចាកឈាននោះ) កាលធ្លើមរណកាល ក៏ទៅកើតជាមួយនឹងពួកទេវតា ដែលកើតក្នុងជាន់អាកាសានញ្ចាយតនៈ ។ ម្នាលភិក្ខុទាំងឡាយ ប្រមាណអាយុរបស់ពួកទេវតា ដែលកើតក្នុងជាន់អាកាសានញ្ចាយតនៈ កំណត់ពាន់កប្ប (២០០០០កប្ប) ។ បុថុជ្ជន ដែលបរិតនៅក្នុងកតនោះ ជាប់ជំពាក់នូវអស់អាយុ គឺកំណត់អស់អាយុទាំងអស់ ដែលជាប្រមាណអាយុ នៃទេវតាទាំងនោះ ហើយក៏ទៅកើតក្នុងនរកខ្លះ ទៅកើតក្នុងកំណើតតិរច្ឆានខ្លះ ទៅកើតក្នុងបិត្តិវិស័យខ្លះ ។ ចំណែកខាងសាវកបស់ព្រះដ៏មានព្រះភាគ ដែលបរិតនៅក្នុងកតនោះ ជាប់ជំពាក់នូវអស់អាយុ គឺថាកំណត់អស់អាយុ

ยาวตกํ เตสํ เอกทิวสมฺปิ อายุปฺปมาณํ ตํ สพฺพํ ขเยเยว ตสฺมึเยว ภเว ปริกฺขียติ ฯ อยมฺปิ โข ภิกฺขเว ปริเสสโต อยมฺปิ อภิปฺปายโต ปฐมา ชราปาการูปมา สุตวโต อริยสาวกสฺส อสุตวโต ปุถุชฺชนสฺส ยถิทํ ตติยา อุปปตฺติยา สติ ฯ ปุน จปรํ ภิกฺขเว ปฐเมปิ ปุคฺคลา ปุคฺคลเว สพฺพโส อากาสานญฺจายตนํ สมติกฺกมฺม อนนฺตํ วิญฺญาณนฺติ วิญฺญาณญฺจายตนํ อุปสมฺปชฺช วิหรนฺติ ฯ เสยฺยถาปิ ตทสฺสาเทติ ตทภินนฺทเนติ ตสฺส จ วิปฺปยุตฺตา อปชฺชติ ตตฺถ ปิโต ตทธิมุตฺตา ตทพฺพหุลวิหารี อปริหีโน กาลงฺกิริยาโย วิญฺญาณญฺจายตนูปคานํ เทวานํ สหพฺยตฺตํ อุปปชฺชติ ฯ วิญฺญาณญฺจายตนูปคานํ ภิกฺขเว เทวานํ จตฺตาฬีส กปฺปสหสฺสานิ อายุปฺปมาณํ ฯ ตตฺร ปุถุชฺชโน ยาวตายุกํ ฐตฺวา ยาวตกํ เตสํ เทวานํ อายุปฺปมาณํ ตํ สพฺพํ ขเยปิ นิรเยปิ ปจฺจติ

តាំងអស់ ដែលជាប្រមាណអាយុរបស់ពួកទេវតាតាំងនោះ ហើយក៏បរិនិព្វានកន្លងកតនោះឯង ។ ម្នាលភិក្ខុតាំងឡាយ នេះជាសេចក្តីថ្លែក នេះជាសេចក្តីអធិប្បាយ នេះជាអំពើផ្សេងៗគ្នា នៃអរិយសាវក អ្នកបេះដឹង នឹងបុថុជ្ជនអ្នកមិនបេះដឹង កាលបើនៅមានគតិកត នឹងចបបត្តិកតនៅឡើយ ។ ម្នាលភិក្ខុតាំងឡាយ ប្រការមួយទៀត បុគ្គលពួកមួយ កន្លងលោកនេះទៅដោយកាសានញ្ចាយតនជ្ឈាន ដោយប្រការតាំងពួន ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុតដូច្នេះ បុគ្គលនោះ ត្រេកអរនឹងឈាននោះ ប្រកាន់នូវឈាននោះ ដល់នូវសេចក្តីត្រេកអរដោយឈាននោះ ឋិតនៅក្នុងឈាននោះ សម្រុកទៅក្នុងឈាននោះ សម្រេចសម្រុងនៅដោយច្រើនក្នុងឈាននោះ មិនសាបសូន្យ (ចាកឈាននោះ) កាលធ្វើមរណកាលទៅ ក៏ទៅកើតជាមួយនឹងទេវតា ដែលកើតក្នុងជាន់វិញ្ញាណញ្ចាយតន: ។ ម្នាលភិក្ខុតាំងឡាយ ប្រមាណអាយុនៃពួកទេវតា ដែលកើតក្នុងជាន់ វិញ្ញាណញ្ចាយតន: កំណត់ប្លុងហ៊ឺនកប្ប (៤ ០ ០ ០ ០ កប្ប) ។ បុថុជ្ជន ដែលបិតនៅក្នុងកតនោះ ដរាបដល់អស់អាយុ គឺថាកំណត់អស់អាយុតាំងអស់ ដែលជាប្រមាណអាយុ នៃពួកទេវតាតាំងនោះហើយ ទៅកើតក្នុងនរកខ្លះ

តិវជ្ជានយោនិមឡ្ហិ កច្ចតិ បិត្តិវិសយម្ហិ កច្ចតិ ។
ភគវាតោ បន សាវកោ តត្ថ យាវតាយុកំ
ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ
សព្ពំ ខេបេត្វា តស្មឹយេវ ភវេ បរិនិព្ពាយតិ ។ អយំ
ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយោ ឥទំ
ឆាឆាការណំ សុត្តវោ អរិយេសាវកស្ស អស្សុតវោ
បុថុជ្ជនេន យទិទំ កតិយា ឧបបត្តិយា សតិ ។
បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ សព្ពសោ
វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិ-
ញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ តទស្សាទេតិ
តំ និកាមេតិ តេន ច វិត្តិំ អាបជ្ជតិ តត្ថ ឋិតោ
តទធិមុត្តោ តព្ពហុលវិហារី អបរិហីនោ កាលំ ករុ-
មានោ អាកិញ្ចញ្ញាយតនូបគានំ ទេវានំ សហព្យតំ
ឧបបជ្ជតិ ។ អាកិញ្ចញ្ញាយតនូបគានំ ភិក្ខវេ
ទេវានំ សដ្ឋិ កប្បសហស្សានិ អាយុប្បមាណំ ។

ទៅកើតកន្លែងកំណើតតិរច្ឆានខ្លះ ទៅកើតក្នុងបិត្តិវិស័យខ្លះ ។ ចំណែកសាវ័ករបស់ព្រះដ៏មានព្រះភាគ បីតនៅក្នុងកាលនោះ ជាបដល់អស់អាយុតឹកំណត់អស់អាយុតាំងអស់ ដែលជាប្រមាណអាយុនៃពួកទេវតាតាំងនោះ ហើយក៏បរិនិព្វានក្នុងកាលនោះឯង ។ ម្នាលភិក្ខុតាំងពីឆ្ងាយនេះជាសេចក្តីថ្លែក នេះជាសេចក្តីអធិប្បាយ នេះជាអំពើផ្សេង ។ គ្នានៃអរិយសាវ័ក អ្នកចេះដឹង នឹងបុថុជ្ជនអ្នកមិនចេះដឹង កាលបើគិតពិតនឹងបបត្តិភពមាននៅឡើយ ។ ម្នាលភិក្ខុតាំងពីឆ្ងាយ មួយទៀត បុគ្គលពួកមួយ ក្នុងលោកនេះ កន្ទងបង់នូវបញ្ចោរណភាគ្យតនជ្ឈាន ដោយប្រការតាំងពួន ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា អ្វីតិចតួចមិនមាន ដូច្នេះ ។ បុគ្គលនោះ ត្រេកអរនឹងឈាននោះ ច្រូងច្រាឈាននោះ ដល់នូវសេចក្តីត្រេកអរដោយឈាននោះ បីតនៅក្នុងឈាននោះ សម្រាកនៅក្នុងឈាននោះ សម្រេចសម្រាន្តនៅដោយច្រើនក្នុងឈាននោះ មិនសាបសូន្យ (ចាកឈាននោះ) កាលធ្វើមរណកាលទៅរួមជាមួយនឹងពួកទេវតា ដែលកើតក្នុងជាន់អាកិញ្ចញ្ញាយតនៈ។ ម្នាលភិក្ខុតាំងពីឆ្ងាយ ប្រមាណអាយុនៃពួកទេវតា ដែលកើតក្នុងជាន់អាកិញ្ចញ្ញាយតនៈ កំណត់ច្រើនមួយហ្មឺនកប្ប (៦០០០០ កប្ប) ។

ตตฺร ปุปฺผฉฑฺฑโก ยาวตายุกานิ ฐตฺวา ยาวตกานิ เตสํ เขปกานิ อายุปฺปมาณานิ ตานิ สพฺพานิ เขเปตฺวา นิรเยปิ ปจฺจติ ติรจฺฉานโยนิยมฺปิ ปจฺจติ ปิตฺติวิสยเมปิ ปจฺจติ ฯ ภควาเตา ปน สาวเกหิ ตตฺร ยาวตายุกานิ ฐตฺวา ยาวตกานิ เตสํ เขปกานิ อายุปฺปมาณานิ ตานิ สพฺพานิ เขเปตฺวา ตสฺมึเยว ภเว ปรินิพฺพายตีติ ฯ อยมฺปิ เขตฺตเว วิเสเสติ อยมฺปิ อธิปฺปายเสฺยว ๙ฐานนฺตรกรณานิ สุตฺวาเตา อริยสาวกสฺส อสฺสุตฺวาตา ปุปฺผฉฑฺฑเนน นิรเยน ตติยา อุปปตฺติยา สติ ฯ ๙เมเขตฺตเว ตโย ปุคฺคลา สนฺตา สํวิชฺชมานา โลกสฺมินฺติ ฯ

(๑๑๙) ตีเณฺว ๙มานิ ภิกฺขเว วิปตฺติโย ฯ กตมา ตีเณฺว ฯ สีลวิปตฺติ จิตฺตวิปตฺติ ทิฏฺฐิวิปตฺติ ฯ กตมา จ ภิกฺขเว สีลวิปตฺติ ฯ ๙ธ ภิกฺขเว เอกจฺโจ ปาณาติปาตี โหติ อทินฺนาทายี โหติ กาเมสุ มิจฺฉาจารี โหติ มุสาวาที โหติ ปิสุณวาจา โหติ ผรุสวาจา โหติ

បុថុជ្ជនបឋមនៅកប្បកតនោះ ជាបដល់អស់អាយុ គឺថាកំណត់អស់អាយុ
តាំងអស់ ដែលប្រមាណអាយុ នៃពួកទេវតាតាំងនោះ ហើយក៏ទៅកើត
កប្បនរកខ្លះ ទៅកើតកប្បកំណើតតិរច្ឆានខ្លះ ទៅកើតកប្បបិត្តិវិស័យខ្លះ ។
ចំណែកខាងសាវករបស់ព្រះដ៏មានព្រះភាគវិញ បឋមនៅកប្បកតនោះ ជាប
ដល់អស់អាយុ គឺថាកំណត់អស់អាយុតាំងអស់ ដែលជាប្រមាណអាយុ
នៃពួកទេវតាតាំងនោះ ហើយក៏បរិនិព្វានកប្បកតនោះឯង ។ ម្នាលភិក្ខុ
តាំងពី្រយ នេះជាសេចក្តីប្លែក នេះជាសេចក្តីអធិប្បាយ នេះជាអំពើផ្សេង។
នៃអរិយសាវក អ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង កាលបើគតិកត
និងទបបត្តិកត មាននៅឡើយ ។ ម្នាលភិក្ខុតាំងពី្រយ បុគ្គលតាំង៣
ពួកនេះ រមែងមាននៅកប្បលោក ។

[๑๑๙] ម្នាលភិក្ខុតាំងពី្រយ វិបត្តិតាំងពី្រយនេះ មាន ៣
យ៉ាង ។ វិបត្តិ៣យ៉ាងដូចម្តេចខ្លះ។ គឺសីលវិបត្តិ១ ចិត្តវិបត្តិ១ ទិដ្ឋិវិបត្តិ១ ។
ម្នាលភិក្ខុតាំងពី្រយ បុះសីលវិបត្តិ ដូចម្តេច ។ ម្នាលភិក្ខុតាំងពី្រយ បុគ្គល
ពួកខ្លះ កង្លោកនេះ ជាអ្នកសំឡាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសកង
កាម ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់

សម្ផប្បលាបី ហោតិ ។ អយំ បុគ្គលោ កិត្តាវ សីលវិបត្តិ ។ តាវតមា ច កិត្តាវ ចិត្តវិបត្តិ ។ ឥធ កិត្តាវ ឯកច្ចោ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ ។ អយំ បុគ្គលោ កិត្តាវ ចិត្តវិបត្តិ ។ តាវតមា ច កិត្តាវ ទិដ្ឋិវិបត្តិ ។ ឥធ កិត្តាវ ឯកច្ចោ មិច្ឆាទិដ្ឋិកោ ហោតិ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលវិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឧបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ អយំ បុគ្គលោ កិត្តាវ ទិដ្ឋិវិបត្តិ ។ សីលវិបត្តិហេតុ ឯ កិត្តាវ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជន្តិ ចិត្តវិបត្តិហេតុ ឯ កិត្តាវ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជន្តិ ទិដ្ឋិវិបត្តិហេតុ ឯ កិត្តាវ សត្តា

ពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះចិត្តវិបត្តិ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិវិបត្តិ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយមិនមានផលការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាកនៃកម្មដែលបុគ្គលធ្វើល្អនិងអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមាន បិតាមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ជាអ្នកព្រមព្រៀងគ្នាប្រតិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសក្នុងលោកក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយពីកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែចិត្តវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយពីកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិវិបត្តិ បានជាសត្វទាំងឡាយ

กายสฺส เภทา ปรมฺมรณา อหายํ ปุคฺคโล วินิปาตํ นิรยํ อุปปชฺชติ ฯ ๙มา ๑๑ กิตฺตาวตา สีลสมฺปนฺโน ฯ สีลสมฺปนฺโน ๙มา กิตฺตาวตา สมฺปนฺนา ฯ กตมา สีลสมฺปนฺนา ฯ สีลสมฺปนฺนา จิตฺตสมฺปนฺนา ทิฏฺฐิสมฺปนฺนา ฯ กตมา จ กิตฺตาวตา สีลสมฺปนฺนา ฯ ๙ฉ กิตฺตาวตา ฌกเขฺวา ญาณาติญาตา ปฏิวิรโต โหติ อนิฏฺฐานาย ปฏิวิรโต โหติ กาเมสุ มิจฺฉาจารา ปฏิวิรโต โหติ มุสาวาทา ปฏิวิรโต โหติ ปิสุณาย วาจาย ปฏิวิรโต โหติ ผรุสาย วาจาย ปฏิวิรโต โหติ สมฺผปฺปลาปา ปฏิวิรโต โหติ ฯ อยํ ปุคฺคโล กิตฺตาวตา สีลสมฺปนฺโน ฯ กตมา จ กิตฺตาวตา จิตฺตสมฺปนฺนา ฯ ๙ฉ กิตฺตาวตา ฌกเขฺวา อนภิชฺฌาลุ โหติ อพฺยาปนฺนจิตฺโต โหติ ฯ อยํ ปุคฺคโล กิตฺตาวตา จิตฺตสมฺปนฺนา ฯ กตมา จ กิตฺตาวตา ทิฏฺฐิสมฺปนฺนา ฯ ๙ฉ กิตฺตาวตา ฌกเขฺวา สมฺมาทิฏฺฐิโก โหติ อวิปรีตทสฺสโน

លុះបែកធ្លាយពងកាយ បន្ទាប់អំពីមរណៈទៅកើតកន្លែងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិមានភាយ៉ាងប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ សម្បទានេះមានភាយ៉ាង ។ សម្បទាភាយ៉ាងដូចម្តេចខ្លះ ។ គឺសីលសម្បទា ១ ចិត្តសម្បទា ១ ទិដ្ឋិសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសីលសម្បទាតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះចិត្តសម្បទាតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ មិនប្រើនដោយអភិជ្ឈា មានចិត្តមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិសម្បទាតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរិតថា

អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ
សុកតទុក្កដានំ កម្មានំ ផលវិបាកោ អត្ថិ អយំ
លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ
បិតា អត្ថិ សត្តា ឧបបាតិកា អត្ថិ លោកេ
សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ
ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា
សច្ឆិកត្វា បវេទេន្តីតិ ។ អយំ បុច្ឆតិ កិក្ខវេ ទិដ្ឋ-
សម្បទា ។ សីលសម្បទាហេតុ ឯ កិក្ខវេ សត្តា
កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ
ឧបបជ្ជន្តិ ចិត្តសម្បទាហេតុ ឯ កិក្ខវេ សត្តា
កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ
ឧបបជ្ជន្តិ ទិដ្ឋិសម្បទាហេតុ ឯ កិក្ខវេ សត្តា
កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ
ឧបបជ្ជន្តិ ។ ឥមា ខោ កិក្ខវេ តិស្សោ សម្បទាតិ ។

ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាកនៃកម្មដែលសត្វធ្វើល្អនឹងអាក្រក់មាន លោកនេះក៏មាន លោកខាងមុខក៏មាន មាតាមាន បិតាមាន ពួកសត្វជាឧបបាតិកៈមាន ពួកសមណព្រាហ្មណ៍ជាអ្នកព្រមព្រៀងគ្នាប្រតិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនឹងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយប្រកាសក្នុងលោកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈ ទៅកើតក្នុងលោកគឺសុគតិនឹងស្ថានសួគ៌ក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែចិត្តសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅកើតក្នុងលោកគឺសុគតិនឹងស្ថានសួគ៌ក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិសម្បទា បានជា សត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺសុគតិនឹងស្ថានសួគ៌ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ សម្បទាមាន ៣ យ៉ាងប៉ុណ្ណេះ ។

[๑๒๐] តិស្សោ ឥមា កិក្ខវេ វិបត្តិយោ ។ កតមា តិស្សោ ។ សីលវិបត្តិ ចិត្តវិបត្តិ ទិដ្ឋិវិបត្តិ ។ កតមា ច កិក្ខវេ សីលវិបត្តិ ។ ឥធ កិក្ខវេ ឯកច្ចោ ចាណាតិចាតី ហោតិ ។បេ ។ សម្ផប្បលាបី ហោតិ ។ អយំ វុច្ចតិ កិក្ខវេ សីលវិបត្តិ ។ កតមា ច កិក្ខវេ ចិត្តវិបត្តិ ។ ឥធ កិក្ខវេ ឯកច្ចោ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ ។ អយំ វុច្ចតិ កិក្ខវេ ចិត្តវិបត្តិ ។ កតមា ច កិក្ខវេ ទិដ្ឋិវិបត្តិ ។ ឥធ កិក្ខវេ ឯកច្ចោ មិច្ឆាទិដ្ឋិកោ ហោតិ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។ បេ ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ អយំ វុច្ចតិ កិក្ខវេ ទិដ្ឋិវិបត្តិ ។ សីលវិបត្តិហេតុ ឥ កិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជន្តិ

[๑๒๐] ម្នាលកិកូតាំងឆ្ពាយ វិបត្តិនេះមាន ๓ យ៉ាង ។ វិបត្តិ ๓ យ៉ាងដូចម្តេចខ្លះ ។ គឺ សីលវិបត្តិ ๑ ចិត្តវិបត្តិ ๑ ទិដ្ឋិវិបត្តិ ๑ ។ ម្នាលកិកូតាំងឆ្ពាយ ចុះសីលវិបត្តិ តើដូចម្តេច ។ ម្នាលកិកូតាំងឆ្ពាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ ពោលពាក្យឥតប្រយោជន៍ ។ ម្នាលកិកូតាំងឆ្ពាយ នេះហៅថា សីលវិបត្តិ ។ ម្នាលកិកូតាំងឆ្ពាយ ចុះចិត្តវិបត្តិ តើដូចម្តេច ។ ម្នាលកិកូតាំងឆ្ពាយ បុគ្គលពួកមួយ ក្នុងលោកនេះ ច្រើនដោយអភិជ្ឈា មានចិត្តប្រកបដោយព្យាបាទ ។ ម្នាលកិកូតាំងឆ្ពាយ នេះហៅថា ចិត្តវិបត្តិ ។ ម្នាលកិកូតាំងឆ្ពាយ ចុះទិដ្ឋិវិបត្តិ តើដូចម្តេច ។ ម្នាលកិកូតាំងឆ្ពាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ។បេ។ ពួកសមណព្រាហ្មណ៍ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសក្នុងលោកក៏មិនមាន ។ ម្នាលកិកូតាំងឆ្ពាយ នេះហៅថា ទិដ្ឋិវិបត្តិ ។ ម្នាលកិកូតាំងឆ្ពាយ ព្រោះហេតុតែសីលវិបត្តិ បានជាសត្វខ្លះឆ្ពាយ លុះបែកធ្លាយកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន

จิตฺตวิปตฺติเหตุ วา... ทิฏฐิวิปตฺติเหตุ วา กิกฺขเว สตฺตา กายสฺส เภทา ปรมฺมรณา อปายํ ทุคฺคตึ วินิปาตํ นิรยํ อุปปชฺชนฺติ ฯ เสยฺยถาปิ กิกฺขเว อปณฺณโก มณิ อุทฺธิเตฺว เยน เยเนว ปติฏฺฐาติ สุปฺปติฏฺฐิตายเว ปติฏฺฐาติ ฯเปฯ เอวเมว โข กิกฺขเว สีลวิปตฺติเหตุ วา สตฺตา กายสฺส เภทา ปรมฺมรณา อปายํ ทุคฺคตึ วินิปาตํ นิรยํ อุปปชฺชนฺติ จิตฺตวิปตฺติเหตุ วา... ทิฏฐิวิปตฺติเหตุ วา สตฺตา กายสฺส เภทา ปรมฺมรณา อปายํ ทุคฺคตึ วินิปาตํ นิรยํ อุปปชฺชนฺติ ฯ ทฺวีหิ โข กิกฺขเว ตีหิ สุจริเตหิ สมนฺนาคตา ฯ ตีหิ ทฺวีหิ กิกฺขเว สมฺปนฺนา ฯ กตเมหิ ตีหิ ฯ สีลสมฺปนฺนา จิตฺตสมฺปนฺนา ทิฏฐิสมฺปนฺนา ฯ กตเมหิ จ กิกฺขเว สีลสมฺปนฺนา ฯ อิธ กิกฺขเว เอกจฺโจ ปาณาติปาตา ปฏิวิรโต โหติ ฯเปฯ สมฺมาปฺปลาปา ปฏิวิรโต โหติ ฯ อยํ วุจฺจติ กิกฺขเว สีลสมฺปนฺนา ฯ กตเมหิ จ กิกฺขเว จิตฺตสมฺปนฺนา ฯ

ព្រោះហេតុតែចិត្តវិបត្តិ... ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយពងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចកូនចាសកា មានជ្រុងខ្ញី ដែលបុគ្គលចោះទៅលើ (ធ្លាក់ចុះមក) តាំងនៅដោយជ្រុងណា ។ រមែងបិតនៅទទឹង (ដោយជ្រុងនោះ ។) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយពងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកក៏មាន ព្រោះហេតុតែចិត្តវិបត្តិ ក៏មាន... ព្រោះហេតុតែទិដ្ឋិវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយពងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិមាន ៣ យ៉ាងប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៣ យ៉ាង ។ សម្បទា ៣ យ៉ាងដូចម្តេច ខ្លះ ។ គឺសីលសម្បទា ១ ចិត្តសម្បទា ១ ទិដ្ឋិសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលសីលសម្បទាតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ វៀរចាកបាណាតិបាត ។ បេ ។ វៀរចាកសម្ផប្បលាបៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលសម្បទា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលចិត្តសម្បទា តើដូចម្តេច ។

៨ឆ កិក្ខវេ ឯកច្ចោ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ ។ អយំ វុច្ចតិ កិក្ខវេ ចិត្ត-សម្បទា ។ កតមា ច កិក្ខវេ ទិដ្ឋិសម្បទា ។ ៨ឆ កិក្ខវេ ឯកច្ចោ សម្មាទិដ្ឋិកោ ហោតិ អវិបរីតទស្សនោ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ ។បេ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ អយំ វុច្ចតិ កិក្ខវេ ទិដ្ឋិសម្បទា ។ សីលសម្បទាហេតុ ក កិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ចិត្តសម្បទាហេតុ ក... ទិដ្ឋិ-សម្បទាហេតុ ក កិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សេយ្យថាបិ កិក្ខវេ អបណ្ណកោ មណិ ឧទ្ធំ ខិត្តោ យេន យេនេវ បតិដ្ឋាតិ សុប្បតិដ្ឋិតំយេវ បតិដ្ឋាតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ មិនច្រើនដោយអភិជ្ឈា
មានចិត្តមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តសម្បទា ។
ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ
បុគ្គលពួកមួយ ក្នុងលោកនេះ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរីតថា
ទានដែលបុគ្គលឲ្យ មានផល ការបូជាធំ មានផល ។បេ។ ពួកសមណៈ
ព្រាហ្មណ៍ ដែលធ្វើឲ្យជាក់ច្បាស់ នូវលោកនេះនឹងលោកខាងមុខ ដោយ
ប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសក្នុងលោក ក៏មាន ។
ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិសម្បទា ។ ម្នាលភិក្ខុទាំងឡាយ
ព្រោះហេតុតែសីលសម្បទា ជាន ជាសត្វទាំងឡាយ លុះបែកធ្លាយពីរាង
កាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោកគឺសុគតិនឹងស្ថានសួគ៌ក៏មាន
ព្រោះហេតុតែចិត្តសម្បទា ... ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិ-
សម្បទា ជាន ជាសត្វទាំងឡាយ លុះបែកធ្លាយពីរាងកាយ បន្ទាប់អំពីមរណៈ
ទៅកើតក្នុងលោកគឺសុគតិនឹងស្ថានសួគ៌ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ
ប្រៀបដូចកូនជ្រូកមានជ្រុង ៦ ដែលបុគ្គលបោះទៅលើ (ធ្លាក់ចុះមក)
តាំងនៅដោយជ្រុងណា ។ រមែងបិតនៅនឹង (ដោយជ្រុងនោះ ។)

ฆานเมว เขา กิเจฺจ สีลสมฺปนฺนาเหตุ ภ สตฺถา กายสฺส เภทา ปรมฺมรณา สุคตึ สคฺคํ โลกํ อุปปชฺชติ จิตฺตสมฺปนฺนาเหตุ ภ... ทิฏฺฐิสมฺปนฺนาเหตุ ภ กิเจฺจ สตฺถา กายสฺส เภทา ปรมฺมรณา สุคตึ สคฺคํ โลกํ อุปปชฺชติ ฯ ส์มา เขา กิเจฺจ ตีสฺส สมฺปนฺนาติ ฯ

(๑๒๑) ตีสฺส ส์มา กิเจฺจ วิปตฺติยา ฯ กตมา ตีสฺส ฯ กมฺมนฺตวิปตฺติ อาชีววิปตฺติ ทิฏฺฐิวิปตฺติ ฯ กตมา จ กิเจฺจ กมฺมนฺตวิปตฺติ ฯ ส์ จ กิเจฺจ ฆกเขฺว ถาณาตีถาตี เหาติ ฯเป ฯ สมฺมปฺปลาปี เหาติ ฯ อยํ วุจฺจติ กิเจฺจ กมฺมนฺตวิปตฺติ ฯ กตมา จ กิเจฺจ อาชีววิปตฺติ ฯ ส์ จ กิเจฺจ ฆกเขฺว มิจฺฉาอาชีเว เหาติ มิจฺฉาอาชีเวน ชีวิตํ กเปฺปติ ฯ อยํ วุจฺจติ กิเจฺจ อาชีววิปตฺติ ฯ กตมา จ กิเจฺจ ทิฏฺฐิวิปตฺติ ฯ ส์ จ กิเจฺจ ฆกเขฺว มิจฺฉาทิฏฺฐิโก เหาติ วิปรีตทสฺสเนา นตฺถิ ทินฺนํ นตฺถิ

ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលសម្បទា ឃានជាសត្វទាំងឡាយ លុះបែកធ្លាយពីរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោកគឺសុគតិនិងស្ថានសួគ៌ក៏មាន ព្រោះហេតុតែចិត្តសម្បទា ... ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិសម្បទា ឃានជាសត្វទាំងឡាយ លុះបែកធ្លាយពីរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺសុគតិនិងស្ថានសួគ៌ ក៏មានកំយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សម្បទាមាន ៣ យ៉ាងប៉ុណ្ណោះ ។

(๑๒๑) ម្នាលភិក្ខុទាំងឡាយ វិបត្តិនេះមាន ៣ យ៉ាង ។ វិបត្តិ ៣ យ៉ាងដូចម្តេចខ្លះ ។ គឺកម្មន្តវិបត្តិ១ អាជីវវិបត្តិ១ ទិដ្ឋិវិបត្តិ១ ។ ម្នាលភិក្ខុទាំងឡាយ បុរេកម្មន្តវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ ជាអ្នកពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា កម្មន្តវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ បុរេអាជីវវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកចិញ្ចឹមជីវិតខុស សម្រេចការរស់នៅ ដោយការចិញ្ចឹមជីវិតខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាជីវវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ បុរេទិដ្ឋិវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល

ยถิจฺฉกํ ฯ เปฯ ยเมกจฺโจ ลาภกาโม ยสกาโม ปุญฺญกาโม สคฺคกาโม ปเวเทติ ฯ อยํ วุจฺจติ กิกฺขาวา นิฏฺฐาปิตา ฯ ตตฺถ ตตฺถ กิกฺขาวา ตีณิ สิกฺขา ปริปูเรยฺย ฯ ตีณิ กตมานิ ฯ กตมา จ กิกฺขาวา อาทิพฺรหฺมจริยกา ฯ กตมา จ กิกฺขาวา อธิสีลสิกฺขา ฯ กตมา จ กิกฺขาวา อธิจิตฺตสิกฺขา ฯ กตมา จ กิกฺขาวา อธิปญฺญาสิกฺขา ฯ อิมา ติสฺโส กิกฺขาโย ยถาปริปูรา ภาเวติ ฯ อยมฺปิ วุจฺจติ กิกฺขาวา นิฏฺฐาปิตา ฯ

๔๘ กิกฺขาวา ปริปูรการี ฯ กตมา จ กิกฺขาวา ปริปูรการี ฯ อิธ กิกฺขาวา ปริปูรการี ภิกฺขุ ปาติโมกฺขสีลสมฺปนฺโน วิหรติ อาจารโคจรสมฺปนฺโน อณุมตฺเตสุ วชฺเชสุ ภยทสฺสาวี สมาทาย สิกฺขติ สิกฺขาปเทสุ ฯ ปาติโมกฺขสีลสมฺปนฺนตาย ปริปูรการี

ការបូជាធំ មិនមានផល ។ បេ ។ ពួកសមណព្រាហ្មណ៍ ដ្បើឲ្យជាក់ច្បាស់នូវលោកនេះ ទើងលោកខាងមុខដោយប្រាជ្ញាដ៏ទគ្គម ដោយខ្លួនឯង ហើយប្រកាសក្តីដ៏លោកក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិមាន ៣ យ៉ាងប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៣ យ៉ាង ។ សម្បទា ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺកម្មន្តសម្បទា ១ អាជីវសម្បទា ១ ទិដ្ឋិសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មន្តសម្បទាតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ។ បេ ។ ជាអ្នកវៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មន្តសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះអាជីវសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកចិញ្ចឹមជីវិតត្រូវ សម្រេចការរស់នៅ ដោយការចិញ្ចឹមជីវិតត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាជីវសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិសម្បទាតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរិតថា មានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ។ បេ ។

យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ អយំ វុច្ចតិ កិក្ខវេ ទិដ្ឋិសម្បទា ។ ឥមា ខោ កិក្ខវេ តិស្សោ សម្បទាតិ ។

[១២២] តីណិមានិ កិក្ខវេ សោចេយ្យានិ ។ កតមានិ តីណិ ។ កាយសោចេយ្យំ វចីសោចេយ្យំ មនោសោចេយ្យំ ។ កតមញ្ច កិក្ខវេ កាយ-សោចេយ្យំ ។ ឥធ កិក្ខវេ ឯកច្ចោ ចាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ ។ ឥទំ វុច្ចតិ កិក្ខវេ កាយសោចេយ្យំ ។ កតមញ្ច កិក្ខវេ វចី-សោចេយ្យំ ។ ឥធ កិក្ខវេ ឯកច្ចោ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ ។ ឥទំ វុច្ចតិ កិក្ខវេ វចី-សោចេយ្យំ ។ កតមញ្ច កិក្ខវេ មនោសោចេយ្យំ ។

ពួកសមណព្រាហ្មណ៍ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ នឹងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសក្នុងលោកនេះក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋសម្បទា ។ ម្នាលភិក្ខុទាំងឡាយ សម្បទាមាន ៣ យ៉ាងប៉ុណ្ណេះ ។

[១៦២] ម្នាលភិក្ខុទាំងឡាយ ការស្អាតនេះមាន ៣ យ៉ាង ។ ការស្អាត ៣ យ៉ាងដូចម្តេចខ្លះ ។ គឺស្អាតកាយ ១ ស្អាតវាចា ១ ស្អាតចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតកាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តខុសក្នុងកាម ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតកាយ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតវាចា តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ វៀរចាកការពោលពាក្យកុហក វៀរចាកការពោលពាក្យញុះញង់ វៀរចាកការពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតចិត្ត តើដូចម្តេច ។

๕๘ กิกฺขาย ปกาสโน อนภิญฺญาสุ ปโหติ อปฺป-ปญฺญตฺตสฺส ปโหติ สมฺมาปฏิปตฺติยา ปโหติ ฯ ๕ธมฺมา วุจฺจนฺติ กิกฺขาย ปโญฺญ สมฺมาปโญฺญ ฯ

(๑๒๓) ตีณีมานิ กิกฺขาย สมฺปโยคานิ กตมานิ ตีณิ ฯ กายสมฺปโยโค วาจาสมฺปโยโค ปญฺญาสมฺปโยโค ฯ กตมา กิกฺขาย กายสมฺปโยโค ฯ ๕ธ กิกฺขาย กิกฺขู ยาวตกา ยถาปฏิปตฺติ ปฏิปตฺติ อธิฏฺฐานา ปฏิปตฺติ ปฏิปตฺติ อปฺปมาทวิหารี ปฏิปตฺติ ฯ ๕ธมฺมา วุจฺจนฺติ กิกฺขาย กายสมฺปโยโค ฯ กตมา กิกฺขาย วาจาสมฺปโยโค ฯ ๕ธ กิกฺขาย กิกฺขู มุสาวาทา ปฏิปตฺติ ปิสุณาย วาจาย ปฏิปตฺติ ผรุสาย วาจาย ปฏิปตฺติ สมฺผปฺปลาปา ปฏิปตฺติ ฯ ๕ธมฺมา วุจฺจนฺติ กิกฺขาย วาจาสมฺปโยโค ฯ กตมา กิกฺขาย ปญฺญาสมฺปโยโค ฯ ๕ธ กิกฺขาย กิกฺขู สพฺเพ ปิ อชฺฌตฺตา กามธาตุ อตฺถิ เม อชฺฌตฺตา กามธาตุ นตฺถีติ ปชานาติ

ម្នាលភិក្ខុទាំងឡាយ បុគ្គលពកមួយ ក្នុងលោកនេះ ជាអ្នកមិនច្រើនដោយអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាការស្អាតចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ការស្អាតមាន ៣ យ៉ាងប៉ុណ្ណេះ ។

(๑๒๓) ម្នាលភិក្ខុទាំងឡាយ ការស្អាតនេះមាន ៣ យ៉ាង ។ ការស្អាតមាន ៣ យ៉ាងដូចម្តេចខ្លះ ។ គឺការស្អាតកាយ ១ ស្អាតវាចា ១ ស្អាតចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតកាយតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកកិរិយាប្រព្រឹត្តិមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតកាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតវាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកវៀរចាកការពោលពាក្យកុហក វៀរចាកការពោលពាក្យញុះញង់ វៀរចាកការពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតចិត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពោះតាមបច្ចន្តៈមាននៅក្នុងខ្លួនក៏ដឹងច្បាស់ថា តាមបច្ចន្តៈមាននៅក្នុងខ្លួនអាត្មាអញ

អសន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ នត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ ។ យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ព្យាបាទំ អត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ ព្យាបាទំ នត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ ។ យថា ច អនុ-ប្បន្នស្ស ព្យាបាទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ព្យាបាទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ព្យាបាទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ អត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ នត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ ។

ពោះកាមច្ឆន្ទៈមិនមាននៅកន្លែងខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមិនមាននៅកន្លែងខ្លួនអាត្មាអញ ។ មួយទៀត កិរិយាកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវកាមច្ឆន្ទៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃកាមច្ឆន្ទៈ ដែលលះបង់បានហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ពោះព្យាបាទមាននៅកន្លែងខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមាននៅកន្លែងខ្លួនអាត្មាអញ ពោះព្យាបាទមិនមាននៅកន្លែងខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅកន្លែងខ្លួនអាត្មាអញ ។ មួយទៀត កិរិយាកើតឡើងនៃព្យាបាទ ដែលមិនទាន់កើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់ព្យាបាទដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀត នៃព្យាបាទដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ពោះថីនមិទ្ធៈ មាននៅកន្លែងខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈ មាននៅកន្លែងខ្លួនអាត្មាអញ ពោះថីនមិទ្ធៈមិនមាននៅកន្លែងខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមិនមាននៅកន្លែងខ្លួនអាត្មាអញ ។

យថា ច អនុប្បន្នស្ស ជីនមិទ្ធស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ជីនមិទ្ធស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ជីនមិទ្ធស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ សន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ អត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ នត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ ។ យថា ច អនុប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ឧទ្ធច្ចកុក្កុច្ចស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ អត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ អសន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ នត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ ។

មួយទៀត កិរិយាកើតឡើងនៃថីនមិទ្ធៈ ដែលមិនទាន់កើតឡើងដោយ
ហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវថីនមិទ្ធៈ ដែល
កើតឡើងហើយដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយា
មិនកើតតទៅទៀតនៃថីនមិទ្ធៈ ដែលលះបង់ហើយដោយហេតុណា ក៏
ដឹងច្បាស់នូវហេតុនោះផង ។ ពោះទុទ្ធច្ចកុក្កុច្ចៈមាននៅកន្លង ក៏ដឹង
ច្បាស់ថា ទុទ្ធច្ចកុក្កុច្ចៈមាននៅកន្លងអាត្មាអញ ពោះទុទ្ធច្ចកុក្កុច្ចៈមិនមាន
នៅកន្លង ក៏ដឹងច្បាស់ថា ទុទ្ធច្ចកុក្កុច្ចៈមិនមាននៅកន្លងអាត្មាអញ ។
មួយទៀត កិរិយាកើតឡើងនៃទុទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើតឡើង
ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវទុទ្ធច្ច-
កុក្កុច្ចៈ ដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ
ផង កិរិយាមិនកើតតទៅទៀតនៃទុទ្ធច្ចកុក្កុច្ចៈ ដែលលះបង់ហើយ
ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ពោះវិចិកិច្ឆា មាន
នៅកន្លង ក៏ដឹងច្បាស់ថា វិចិកិច្ឆាមាននៅកន្លងអាត្មាអញ ពោះវិចិកិច្ឆា
មិនមាននៅកន្លង ក៏ដឹងច្បាស់ថា វិចិកិច្ឆាមិនមាននៅកន្លងអាត្មាអញ ។

យថា ច អនុប្បន្នាយ វិចិកិច្ឆាយ ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នាយ វិចិកិច្ឆាយ បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនាយ វិចិកិច្ឆាយ អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ ឥទំ វុច្ចតិ កិក្ខវេ មនោសោចេយ្យំ ឥមានិ ខោ កិក្ខវេ តីណិ សោចេយ្យានីតិ ។

កាយសុចឹ វាចាសុចឹ

ចេតោសុចិមនាសវំ

សុចឹ សោចេយ្យសម្បន្នំ ។

អាហុ និច្ចាតថាបកន្តិ ។

(๑๒๔) តីណីមានិ កិក្ខវេ មោនេយ្យានិ ។ កតមានិ តីណិ ។ កាយមោនេយ្យំ វចីមោនេយ្យ

មួយទៀត កិរិយាកើតឡើងនៃវិចិកិច្ឆា ដែលមិនទាន់កើតឡើង ដោយ
ហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់វិចិកិច្ឆាដែល
កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង
កិរិយាមិនកើតតទៅទៀតនៃវិចិកិច្ឆា ដែលកើតឡើងហើយ ដោយ
ហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀត
នៃវិចិកិច្ឆា ដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុ

នោះផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតចិត្ត ។ ម្នាលភិក្ខុ
ទាំងឡាយ ការស្អាតមាន ៣ យ៉ាងប៉ុណ្ណេះ ។

អ្នកប្រាជ្ញទាំងឡាយ ពោលចំពោះបុគ្គល អ្នកស្អាត
កាយ ស្អាតវាចា ស្អាតចិត្ត មិនមានអាសវៈ ជា
អ្នកស្អាត បរិបូណ៌ដោយការស្អាត ថាជាបុគ្គលមាន
ប្រាជ្ញាដ៏ប្រសើរហើយ ។

(๑๒๔) ម្នាលភិក្ខុទាំងឡាយ តាពជាអ្នកប្រាជ្ញនេះមាន ៣ យ៉ាង ។
៣ យ៉ាងគឺអ្វីខ្លះ ។ គឺតាពជាអ្នកប្រាជ្ញផ្លូវកាយ ๑ តាពជាអ្នកប្រាជ្ញផ្លូវវាចា๑

មនោមោនេយ្យំ ។ កតមញ្ច កិក្ខវេ កាយមោនេយ្យំ ។ ឥធ កិក្ខវេ កិក្ខុ ចាណាតិចាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិ-វិរតោ ហោតិ ។ ឥទំ វុច្ចតិ កិក្ខវេ កាយមោនេយ្យំ ។ កតមញ្ច កិក្ខវេ វចីមោនេយ្យំ ។ ឥធ កិក្ខវេ កិក្ខុ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ ។ ឥទំ វុច្ចតិ កិក្ខវេ វចីមោនេយ្យំ ។ កតមញ្ច កិក្ខវេ មនោ-មោនេយ្យំ ។ ឥធ កិក្ខវេ កិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥទំ វុច្ចតិ កិក្ខវេ មនោមោនេយ្យំ ។ ឥមានិ ខោ កិក្ខវេ តីណិ មោនេយ្យានីតិ ។

ភាពជាអ្នកប្រាជ្ញផ្លូវចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្លូវកាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កិកកធសាសនានេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្លូវកាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្លូវវាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កិកកធសាសនានេះ វៀរចាកការពោលពាក្យកុហក វៀរចាកការពោលពាក្យញុះញង់ វៀរចាកការពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្លូវវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្លូវចិត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កិកកធសាសនានេះបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្លូវចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកប្រាជ្ញមាន ៣ យ៉ាងប៉ុណ្ណេះ ។

កាយមុនិ ភាចាមុនិ

ចេតោមុនិមនាសវំ

មុនិំ មោនេយ្យសម្បន្នំ

អាហុ សព្ពប្បហាយិនន្តិ ។

អាថាយិកវគ្គោ ទុតិយោ ។

តស្សុទ្ទានំ

អាថាយិកោ ទុល្លភោ ច

អប្បមេយ្យំ អនេញ្ជកំ

អយំ អបណ្ណកម្មន្តោ

ទ្វេ ច សោចេយ្យមោនេយ្យានិ ។

អ្នកប្រាជ្ញតាំងឆ្ងាយ ពោលចំពោះបុគ្គល ដែលជា
អ្នកប្រាជ្ញផ្លូវកាយ ផ្លូវវាចា ផ្លូវចិត្ត មិនមានអាសវៈ
ជាអ្នកប្រាជ្ញ បរិបូណ៌ដោយភាពជាអ្នកប្រាជ្ញ ថាជា
អ្នកមានបាបលះបង់អស់ហើយ ។

ចប់ អាបាយិកវគ្គទី ២ ។

ឧទ្ទាននៃអាបាយិកវគ្គនោះគឺ

ពោលអំពីបុគ្គលទៅកាន់អបាយ ១ អំពីបុគ្គលរកបាន
ដោយក្រ ១ អំពីអប្បមេយ្យបុគ្គលជាដើម ១ អំពី
បុគ្គលបានអរូបជ្ឈាន មិនញាប់ញ័រ ១ អំពីវិបត្តិ
មានសេចក្តីប្រៀបដោយបាសាកា មានផ្ទៃក្រាំមួយ ១
អំពីកម្មវិបត្តិជាដើម ១ អំពីការស្អាតមានពីរលើក ១
អំពីភាពជាអ្នកប្រាជ្ញ ១ ។

កុសិនារវគ្គោ

[១៤៥] ឯវំ សុតំ ភគវា កុសិនារាយំ
វិហរតិ អនិរុទ្ធេ វនសណ្ឌេ ។ តត្រ ខោ ភគវា
ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ
ភគវតោ បច្চស្សោសុំ ។ ភគវា ឯតទវោច ឥធ
ភិក្ខវេ ភិក្ខុ រញ្ញោវ តាមំ ភ ឯកមំ ភ ឧប-
ដ្ឋិស្សាយ វិហរតិ ។ តមេនំ ភហាមតិ ភ ភហាមតិ-
បុត្តោ ភ ឧបសង្កមិត្វា ស្វាតនាយ ភត្តេន
និមន្តេតិ អាភន្ទមានោ ភិក្ខវេ ភិក្ខុ អធិវាសេតិ ។
សោ តស្សា រត្តិយា អច្চយេន បុព្ពណ្ហសមយំ
និវាសេត្វា បត្តចីវរមាទាយ យេន តស្ស ភហាមតិស្ស
ភ ភហាមតិបុត្តស្ស ភ និវេសនំ តេនុបសង្កមតិ
ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទតិ ។ តមេនំ
សោ ភហាមតិ ភ ភហាមតិបុត្តោ ភ បណីតេន
ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេតិ
សម្បវារេតិ ។ តស្ស ឃំ ភោតិ សាធុ

កុសិនារវគ្គ

(១២៩) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃ ឈ្មោះពលិហរណៈ(១) ជិតក្រុងកុសិនារា ។ កាលនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកងសាសនានេះ ចូលទៅនៅអាស្រ័យនឹងស្រុកឬនិគមណាមួយ ។ ឯគហបតីឬគហបតិបុត្រ ចូលទៅរកភិក្ខុនោះទើមន្តដោយកត្តា ដើម្បីធានក្នុងថ្ងៃស្អែក ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលចង់ធានា ក៏ទទួលទើមន្ត ។ លុះកន្ទងរាត្រីនោះទៅ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រនឹងចីវរ ក្នុងវេលាព្រឹក រួចចូលទៅកាន់លំនៅគហបតីឬគហបតិបុត្រនោះ លុះចូលទៅដល់ហើយ អង្គុយលើអាសនៈដែលគេក្រាលបម្រុងទុក ។ គហបតីឬគហបតិបុត្រនោះ ក៏ទើមន្តភិក្ខុនោះឲ្យធានឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារដ៏ផ្ដែតផ្ដង់ដោយដៃខ្លួនឯង ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រពៃណាសង្ឃ

---

១ ព្រៃដែលកន្លែងដែលមហាជនតាំងគ្រឿងបូជា ទៅបូជាឬកប្រតិសាច ។ អដ្ឋកថា ។

វត មាយំ គហបតិ វា គហបតិបុត្តោ វា បណីតេន
ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេតិ
សម្បវារេតីតិ ។ ឯវម្បិស្ស ហោតិ អហោ វត មាយំ
គហបតិ វា គហបតិបុត្តោ វា អាយតឹបិ ឯវរូបេន
បណីតេន ខាទនីយេន ភោជនីយេន សហត្ថា
សន្តប្បេយ្យ សម្បវារេយ្យាតិ ។ សោ តំ បិណ្ឌបាតំ
កឋិនោ មុច្ឆិតោ អវជ្ឈាបន្នោ អនាទីនវទស្សាវី
អនិស្សរណប្បញ្ញោ បរិភុញ្ជតិ ។ សោ តត្ថ កាម-
រាគក្ខត្តោ រាគក្ខត្តោ ព្យាបាទរាគក្ខត្តោ រាគក្ខត្តោ វិហឹសា-
រាគក្ខត្តោ រាគក្ខត្តោ ។ ឯវរូបស្សាហំ កិក្ខវេ កិក្ខុនោ
និន្នំ ន មហាមលំ វទាមិ ។ តំ កិស្ស ហេតុ ។
បមត្តោ ហិ កិក្ខវេ កិក្ខុ វិហរតិ ។ ឥធ បន
កិក្ខវេ កិក្ខុ អញ្ញតរំ គាមំ វា និគមំ វា ឧប-
និស្សាយ វិហរតិ ។ តមេនំ គហបតិ វា គហបតិ-
បុត្តោ វា ឧបសង្កមិត្វា ស្វាតនាយ ភត្តេន និមន្តេតិ

គហបតីឬគហបតិបុត្រនេះ និមន្តអញ្ជើញឲ្យឆានាំឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារ ដ៏ផ្ដិតផ្ដង់ ដោយដៃខ្លួនឯង ។ កិក្ខុនោះ ក៏គិតយ៉ាងនេះទៀតថា ធ្វើម្ដេចហ្ន៎ ឱងបានគហបតីឬគហបតិបុត្រនេះ និមន្តអញ្ជើញឆានាំឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ដិតផ្ដង់ មានទំនងយ៉ាងនេះ ដោយដៃខ្លួនឯង តទៅទៀតអេះ ។ កិក្ខុនោះ មានចិត្តផ្លែកផ្លួស ជ្រួលជ្រប់ល្មោភ ជាអ្នកមិនឃើញទោស មិនមានបញ្ញាជាគ្រឿងរលាស់ខ្លួនចេញ បរិភោគនូវបិណ្ឌបាតនោះ ។ កិក្ខុនោះ រមែងត្រិះរិះនូវកាមវិតក្កៈផង ត្រិះរិះនូវព្យាបាទវិតក្កៈផង ត្រិះរិះនូវវិហឹសាវិតក្កៈផងក្នុងបិណ្ឌបាតនោះ ។ ម្នាលភិក្ខុទាំងឡាយ ពានដែលគេយកឲ្យហើយជល់ភិក្ខុមានសភាពយ៉ាងនេះ តថាគតមិនហៅថាជាពានមានផលច្រើនទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុមានសេចក្ដីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ចូលទៅនៅអាស្រ័យនឹងស្រុកឬនិគមណាមួយ ។ ឯគហបតីឬគហបតិបុត្រចូលទៅរកភិក្ខុនោះ និមន្តដោយភត្ត ដើម្បីឆានាំភិក្ខុ ថ្ងៃស្អែក

ภาเคยฺยมาโน ภิกฺขเว ภิกฺขุ อนภิรโตติ ฯ
โส ตสฺส รตฺติยา อจฺจเยน ปุพฺพณฺหสมยํ
นิวาเสตฺวา ปตฺตจีวรมาทาย เยน ตสฺส คหปติ-
สฺส วา คหปติปุตฺตสฺส วา นิเวสนํ เตนุปสงฺกมติ
อุปสงฺกมิตฺวา ปญฺญตฺเต อาสเน นิสีทติ ฯ ตมेनं
โส คหปติ วา คหปติปุตฺโต วา ปณีเตน
ขาทนีเยน โภชนีเยน สหตฺถา สนฺตปฺเปติ
สมฺปวาเรติ ฯ ตสฺส น ฆวํ โหติ สาธุ ว
มายํ คหปติ วา คหปติปุตฺโต วา ปณีเตน
ขาทนีเยน โภชนีเยน สหตฺถา สนฺตปฺเปติ
สมฺปวาเรตีติ ฯ ฆวมสฺส น โหติ อโห ว
มายํ คหปติ วา คหปติปุตฺโต วา อายตึ
ฆวาเปน ปณีเตน ขาทนีเยน โภชนีเยน
สหตฺถา สนฺตปฺเปยฺย สมฺปวาเรยฺยาติ ฯ โส
ตं ปิณฺฑาตํ อกสิโต อมุจฺฉิโต อนชฺฌาปนฺโน
อาทีนวทสฺสาวี นิสฺสรณปญฺโญ ปริภุญฺชติ ฯ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបង់ធាន់ក៏ទទួលនិមន្ត ។ លុះកន្ទុងភត្រនោះ
ទៅ ភិក្ខុនោះស្លៀកសង្ឃាដ៏ប្រជាប់ជាត្រនឹងចីវរ ក្នុងវេលាព្រឹក រួចចូលទៅ
កាន់លំនៅ នៃគហបតី ឬគហបតិបុត្រនោះ លុះចូលទៅដល់ហើយ
អង្គុយលើអាសនៈដែលគេក្រាលបម្រុងទុក ។ គហបតី ឬ គហបតិបុត្រ
នោះ ក៏និមន្តភិក្ខុនោះ ឲ្យឆាន់ផ្អែមស្អប់ស្អល់ ដោយខាទនីយភោជនី-
យាហារដ៏ផ្ងួតផ្ងង់ ដោយដៃខ្លួនឯង ។ ភិក្ខុនោះ មិនមានសេចក្តីត្រិះរិះ
យ៉ាងនេះថា ប្រពៃណាស់ហ្ន៎ គហបតីឬគហបតិបុត្រនេះនិមន្តអញឲ្យឆាន់
ផ្អែមស្អប់ស្អល់ ដោយខាទនីយភោជនីយាហារដ៏ផ្ងួតផ្ងង់ដោយដៃខ្លួនឯង ។
តាំងមិនមានសេចក្តីត្រិះរិះ យ៉ាងនេះថា ធ្លាប់ម្តេចហ្ន៎ នឹងបាននគហបតី ឬ
គហបតិបុត្រនេះ និមន្តអញឲ្យឆាន់ផ្អែមស្អប់ស្អល់ ដោយខាទនីយភោជ-
នីយាហារ ដ៏ផ្ងួតផ្ងង់មានទំនងដូច្នេះ ដោយដៃខ្លួនឯងតទៅទៀតឡើយ ។
ភិក្ខុនោះ មិនផ្តេកផ្តួល មិនជ្រុលជ្រប់ មិនស្មោក ជាអ្នកឃើញទោស
មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ បរិភោគនូវបិណ្ឌបាត្រនោះ ។

